# រឿង មហាចោរនៅទល់ដែន

**ភាគទី២០**

ទឹកភ្នែកក៏ហូរចេញពីភ្នែកមានន្ទធ្លាក់ដល់ដី។ អតីតសង្សារនាងទេវីទឹកសង្វេគខ្លួនពន់ពេក។ បុរសពុំដែលយំសោះ តែក្នុងពេលនេះអ្នកយំ ។ អ្នកនិយាយក្នុងចិត្តថា៖

- ទេវីអូន ! បងព្រាត់ពីអូនតាំងពីពេលនេះហើយ ! អូនជាគូកម្ម នឹងបងទេ ។ បងមិនធ្វើអ្វីដល់អូនទេ ! កុំព្រួយ ។ បងមិនចងពៀរទេ។ សូមអូនទៅរស់ជាមួយគូថ្មីរបស់អូនចុះ រស់ឲ្យបានសប្បាយតាមបំណងចិត្តអូនចុះ។ បងមិនខឹងទេ ពីព្រោះបងធ្លាប់ដែលបានរួមរក្សរូបអូនហើយ ។ បងមានជ័យជំនះលើអូនជានិច្ច មានតែអូនទេដែលចោលបងនោះ ចាញ់បង ។ បងឈប់ស្រលាញ់អូនទៀតហើយព្រោះអូនស្រលាញ់គេ។ បងមិនស្តាយអូនទេព្រោះអូនមិនស្តាយបង។ ពីពេលនេះទៅអូនដើរផ្លូវមួយ បងដើរផ្លូវមួយ ព្រោះផ្លូវយើងដើរនោះវាបែកគ្នា ។ អូនមានសង្សារថ្មី បងដើរទៅមុខតែម្នាក់ឯង គ្មានសង្សារ ។ អូននៅតែមានទុក្ខ បងផុតអស់ទុក្ខហើយ ។ អូននៅតែមានចំណងចង បងទៅណាក៏បានធ្វើអ្វីក៏បាន ដេកត្រង់ណាក៏បាន បាយត្រង់ណាក៏បាន តាមចិត្តឥតចំណង បងមានប្រៀបលើអូនជានិច្ច ព្រោះថាបើប្តូរប្រុសរបស់អូននឹងបង គង់ឃើញថាបងគ្រាន់បើជាងប្រាកដទាំងផ្លូវចិត្ត ទាំងផ្លូវលើសីលធម៌ ទាំងផ្លូវមនុស្សធម៌ ទាំងផ្លូវតម្រិះវិជ្ជា ទាំងផ្លូវបុណ្យសក្តិទាំងផ្លូវថ្ងៃថ្នូរ។ លើពិភពផែនដីនេះ តើអូនរកមនុស្សណាឲ្យបានដូចបងទៀតទេ ? ។ បងជាមនុស្សចេះជួយសង្គ្រោះគេ ដោយមិនគិតគ្រោះខ្លួន ចេះគោរពស្រលាញ់គេជាងស្រលាញ់ខ្លួនឯង ចេះឈឺឆ្អាលដល់រឿងគេដោយឥតគិតដល់រឿងខ្លួនហួសហេតុ ចេះជួយកិច្ចការឲ្យគេ ហ៊ានធ្វើការឲ្យគេ ទោះតែម្នាក់ឯងក៏ហ៊ានធ្វើដែរ។ ឱ! អូនទេវី! អូនស្រលាញ់គូថ្មីព្រោះអ្វី ? ព្រោះប្រាក់មែនទេ? ព្រោះគេចេះសប្បាយហ៊ឺហា ព្រោះគេចេះបញ្ឆោត ចេះបោកផងមែនទេ ?។ ទេវីអូន ! បងពុំចេះដូចគេទេ ។ ហេតុនេះ សេចក្តីសំរេចវាសនាអូន គឺអូន។ បងទុកឯកសិទ្ធិនេះលើអូនចុះ តែបងគ្រាន់តែអាណិតអូនដោយស្រីមើលតំលៃមនុស្សខុស។ ទេវីអូន ! បងខំបំភ្លេចរឿងអូន និង បងឲ្យភ្លេចសូន្យពីពេលនេះទៅ។

អត្ថបទដោយ៖ មាស សុភាព

ព្រះអាទិត្យជ្រៀងជ្រេគងលើភ្នំស្វាយហើយ។ ពពកក្រហមឆ្អៅនៅផ្តុំរាយមាយត្រង់នេះត្រង់នោះ ។ ឃើញមេឃចិត្តកើតក្តីសង្វេគដោយនឹករឭកដល់ពេលដែលទើបលោកត្រូវឆេះកល្បទៅអនាគត។ គឺក្នុងពេលចុងបំផុតនេះហើយ ដែលមនុស្សត្រូវរលាយរូប រលាយខន្ធប្រាសចាកអស់ទុក្ខផងទាំងពួង។ ឱ! គឺថ្ងៃគងភ្នំនេះហើយដែលលោកអ្នកចាំបានថា មានន្ទសន្យាជួបកាមាជាប្អូន។ មានន្ទស្ទុះលោតលើខ្នងសេះ បំផាយត្រង់ឆ្ពោះទៅដើមពោធិ៍កណ្តាលស្រែដែលបាននិយាយទុក។ តាំងពីព្រឹកមក អ្នកលេបបាយពុំរួច ដេកពុំលក់ចេះតែរសាប់រសល់។ លុះដល់ទីកំណត់អ្នកលោតចុះពីលើខ្នងអាជានេយ្យដែលអ្នកចងនៅជិតនោះ។ បុរសច្រត់កែងដៃទាំងពីនៅចង្កេះដើរចុះដើរឡើង មើលនាយអាយរួចឈរគិតរឿងដដែលតែមួយ គឺរឿងនាងទេវីជាភរិយាក្បត់ចិត្តអ្នក។

នៅជើងមេឃ សេះមួយទៀតផាយកាន់តែជិតមក។ មានន្ទឈប់ឈរនៅស្ងៀមមើលសេះនេះ។ លុះបានមកដល់ជិត អ្នកជិះសេះលោត ចុះមកដីលែងសេះឲ្យបរិភោគស្មៅទើបមកគោរពមានន្ទយ៉ាងគួរសម។ ដោយឥតមាននិយាយមួយម៉ាត់ មានន្ទហូតដាវខ្វាកប្រាប់ថា៖

- កាមាប្អូនប្រុងខ្លួន ពីព្រោះបងបានសន្យាថាសំលាប់អាចោរលួច ប្រពន្ធគេឲ្យអស់ពីដែនដីខ្មែរ។
- មានជាការអីបង !

កាមាញញឹម ក៏ហូតដាវវិញ ដាវមានន្ទកាប់ឆ្វេងឮឆាំងៗ រន្ទើនគ្នារន្ទំដូចលាចផ្ទុះ។ តែកាមាកាត់ឮច្រែស ៗ ដូចសូរផាវ។ មានន្ទកាប់ខាងស្តាំប៉ាំង ៗ សូរជាប់ប្រកិតគ្នា ។ កាមារងជាប់យ៉ាងអង់អាច។ មានន្ទគ្រវាសដាវកាប់ពីលើប៉ាំងៗ។ កាមាវាសដាវរងបានទៀត មានន្ទចាក់បណ្តើរសើចបណ្តើរ

- យើ ! ប្អូនឯងគ្រាន់បើឥឡូវ!
- បាទ ! ល្មមតែស៊ីសងបានដែរ ។ ហ៊ី សុំជូនបងវិញម្តង!

ក្នុងពេលនោះ ដាវកាមារហ័សដូចរន្ទះ ស្ទុះវាត់មានន្ទខាងឆ្វេងត្រឹមចង្កេះ រួចរត់វឹងទៅវះខាងស្តាំ រួចលោតមកពីលើវិញ។ បើភ្នែកពុំរឹង ស្មារតីពុំបាន ប្រហែលជាពុំអាចរងនឹងមុខដាវ

អត្ថបទដោយ៖ មាស សុភាព

ទាំងពីរយ៉ាងដែលមានទម្ងន់មហិមានេះទេ។ តែមានន្ទវៃណាស់ រងទាន់ព្ធប៉ែស។ បែកព្រាយព្រិចៗ។ កាមាសើចនិយាយម្តងថា៖

- យើ ! គ្រាន់បើដែរ។

មានន្ទសើចតបវិញ

- មិនអ្វីទេ !

លំដាប់នោះគេឮសូរតែដាវរឹតៗ ផាំងៗ គួរស្ញើបក្រៃពេក។ ជនទាំងពីរសុទ្ធសឹងតែចំណានក្នុងវិធីកាន់អាវុធ។ ជនទាំងពីរជួនកាល ជួបជិតគ្នា ស្អិតដូចតាំងម៉ែ ជួនកាលថយឆ្ងាយពីគ្នា។ ជួនកាលមានន្ទជាបង់ជំពប់ដើងដួល  កាមាស្ទុះទៅបម្រុងសម្លាប់ចោល  តែមានន្ទគេចផុតបណ្តាលឲ្យកាមាជ្រុលខ្លួនដាំទីង នឹងដី។ រួចក្រោកឡើងទាំងពីរវិញបន្ទាន់បន្ទាប់គ្នា ចុងដាវក៏ប្រកៀកប្រកិតគ្នាជាថ្មី។ កាមាដួលវិញ មានន្ទស្ទុះទៅសង្កត់ពីលើ ប្រឹងរមួតដៃទប់គ្នាកុំឲ្យចុងដាវផ្ទាប់ជាប់នឹងកខ្លួន រួចធាក់គ្នាដួលផ្កាប់ផ្ងារ ។ មានន្ទដួលវិញ កាមាស្ទុះទៅចាក់បុកជញ្ជ្រាំពីលើដូចគេរុតត្រី។ តែមានន្ទគេចឆ្វេងស្តាំ . . . ផុត។ រួចផ្ទៃដាវទាំងគូមកប្រកួតគ្នាវិញជដែលយ៉ាងស្វិតស្វាញ។

មានន្ទមានវាចាថា៖

- អញទុកចិត្តឯង។ អញជឿសម្បថឯង ព្រោះឯងស្បថឲ្យអញ ឯងមកក្បត់អញវិញ។

កាមាសើច

- ហ៊ីៗ។ មនុស្សក្បាលខ្មៅ គ្មានសម្បថឯណា គ្មានពាក្យសច្ចាឯណាធំជាងចិត្តទេ។
- អញប្រដៅឯងឲ្យដឹងបន្តិច!
- ឥតប្រយោជន៍ទេបង ! ខ្ញុំប្រដៅបងឲ្យចេះស្រលាញ់ស្រី កុំឲ្យទុកចិត្តស្រី។
- បើក្នុងពេលនេះ អញសំលាប់ឯងមិនបាន អញសុខចិត្តស្លាប់។
- ប្រាកដហើយ!

អត្ថបទដោយ៖ មាស សុភាព

- អញយកឈាមឯងលាងអាម៉ាស់ដែលឯងបានប្រព្រឹត្ត។
- តាមចិត្ត!
- អញកាត់ក្បាលឯងដោតឲ្យអ្នកផងមើល។
- តាមត្រូវការ!
- ឯងនេះហៅចំជាព្រហើន!
- ពិតមែន អ្នកណាមិនស្គាល់កាមា ? បងឯងនេះជាមនុស្សយ៉ាប់ណាស់ បានប្រពន្ធមួយ ប្រពន្ធនោះក្បត់ ហាស់ៗ ។
- លុះកាមានិយាយដូច្នោះ មានន្ទនឹកខឹងនាងទេវីក្រៃពេក។ រូបនាងលេចចេញនៅចុងដាវ លេចចេញនៅមុខអ្នក ខាំធ្មេញដាក់អ្នក សម្លក់អ្នក រូបនេះញញឹមដាក់អ្នក សំពះអ្នក អង្វរអ្នក។ មានន្ទក្លេចនឹកដល់អាវុធដែលកំពុងកាន់ ស្រាប់តែ . . . អុ ! ស្រាប់តែចុងដាវរបស់កាមា ស្ទុះរ៉ឺតមកបុកចំដើមទ្រូងអ្នក។ បុរសផ្អៀងខ្លួនតែពុំផុត ចុងដាវរុកចូលក្នុងស្មាស្តាំ ឈាមហូរខ្ទាយក្រហមឆ្អៅ។ ចុងដាវធ្វើឲ្យអ្នកចុកពើតក្រៃលែង។ កាមា បានឱកាសនេះវាយផ្តាច់ព្រ័ត្រ កាប់ឆ្វេងស្តាំ ពីចំហៀង មានន្ទប្រឹងរងគេចយ៉ាងត្រដរ។ ក្នុងពេលនោះមានន្ទដឹងខ្លួនឡើងថា អ្នកកំពុងតស៊ូដើម្បីរស់ ទើបអ្នកផ្លាស់ដាវមកកាន់ដៃឆ្វេងវិញចាក់តទៅទៀត។

កាមាសើចយ៉ាងរីករាយ។

- ម៉េចបង បងថាយកឈាមខ្ញុំ ឥឡូវគឺបងទេដែលហូរឈាម . . . ។
- អត់ទាន់អីទេ ! ប្អូន !

សូរដាវក៏លាន់ឮរន្ថើនយ៉ាងខ្លាំងឡើងវិញដដែល។

និយាយពីអ្នកស្រុកដែលដឹកគោបញ្ចូលក្រោល ដើរជិតនោះ កាលបើបានឃើញមានន្ទនិងកាមាប្រកាប់ប្រចាក់គ្នាដូច្នោះ មានសេចក្តីតិតភ័យយ៉ាងខ្លាំង រត់ទៅភូមិប្រាប់អស់ញាតិមិត្តឲ្យមកជួយជាប្រញាប់។ តែព្រះអាទិត្យលិចបាត់ទៅហើយ។ ពន្លឺព្រះចន្ទក៏បំភ្លឺឡើងស្រាងៗ។ អ្នកស្រុកខ្លះអុចចង្កៀង ខ្លះអុជចន្លុះរត់មកទីសមរភូមិនៃបងប្អូនទាំងពីរនោះ មានចំនួន

ច្រើនអនេក ។ តែគ្មានអ្នកណាមួយហ៊ានចូលឃាត់សោះ ពីព្រោះដាវទាំងពីរនៅតែប្រកៀកជាប់គ្នាជានិច្ច ។ ដល់ឃើញអ្នកស្រុកមកកាន់តែច្រើនឡើង មានន្ទប្រកិតដាវរបស់កាមាជាប់រួចនិយាយថា៖

- ចូលប្អូនប្រុងខ្លួនឲ្យមែនទែនហ្ន៎ា !
- ខ្ញុំអត់ភ័យទេ បងឯងចាក់ដៃឆ្វេងនោះ!
- ដៃឆ្វេងបង ក៏ប្រើការបានដូចដៃស្តាំ ប្រុងអូន !

ដាវមានន្ទបុករុញៗទៅមុខប៉ាច់ៗ ដូចព្រួញដែលដេញកាមាជាប់។ កាមាភ័យនឹងចុងដាវនេះដែរ ពីព្រោះឃើញថាបងផ្លាស់ស្នៀតថ្មីហើយទម្ងន់ដៃឃើញថា ខ្លាំងជាងធម្មតារកទប់ស្ទើរពុំរួច តែកាមាប្រឹងធ្មក់រកឱកាសល្អ។ ក្រោយមកស្រាប់តែដាវមានន្ទវាត់ក្រឡាច់ចំពាក់កណ្តាលដើមទ្រូង កាមាធ្វើឲ្យកាមាដួលតូង ក្រាបស្រប៉ាបលើដីឈាមហូរគគុក។ កាមាប្រឹងក្រោកឡើងទៀត តែដួលទៅវិញ ។ អ្នកស្រុកលាន់មាត់ស្រែកថា អូយគ្រប់ៗគ្នា។ កាមាប្រែខ្លួនធ្វើអ៊ឹះៗ។ មានន្ទដែលអស់កម្លាំងណាស់ទៅហើយ លុះឃើញកាមាអស់តដៃបាន ក៏ជូតដាវដែលប្រលាក់ឈាម ស៊កចូលក្នុងស្រោមវិញ ដើរទាំងធេងធោងៗ ទៅរកសេះ។ ដល់ហើយអ្នកឡើងលើខ្នងអស្សពាហ៍បំបោលទៅខាងទិសឯត្បូងក្នុងងងឹតបាត់ទៅ។

អ្នកស្រុកដែលទៅមើលទាំងប៉ុន្មាន ក៏លើកកាមាឡើង ខ្លះជួយជូតឈាមខ្លះជួយស្រែកហៅ តែកាមាសន្ទប់បាត់ស្មារតីយូរណាស់ទៅហើយ ។ អ្នកសួរដោយកិតភ័យថា៖

- ស្លាប់ហើយ ឬអី ?
- ទេ ! មិនទាន់ស្លាប់ទេ!
- របួសតិច រឺខ្លាំង ?
- របួសខ្លាំងណាស់ មិនដឹងជាស្លាប់ ឬរស់ទេ!

អ្នកទាំងអស់គ្នាក៏សែងកាមាយកទៅគេហដ្ឋានព្រះកម្ពុតទាំងយប់ឥតបង្អង់ឡើយ៕

**(សូមរង់ចាំតាមដានភាគទី២១ នៅសប្តាហ៍ក្រោយ)**

អត្ថបទដោយ៖ មាស សុភាព